## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**
សំណុំរឿងព្រហ្មទណ្ឌលេខ ៧១០
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ ៤៧០
ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤
សំណុំរឿងជំនុំជម្រះលេខ ៩២៩
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤
**សាលក្រមព្រហ្មទណ្ឌ**
**លេខ ១៣៤ "ខ" / ១១៣៦**
**ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤**

### តាងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការនៅថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ វេលាម៉ោង ២៖៣០ នាទីរសៀល សាលសវនាការ ខ១ និងប្រកាសសាលក្រមនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប
លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឈ្មោះ [redacted] រិន

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧១០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កម្រិតវប្បធម៌គ្មាន មុខរបរកសិករ ប្រពន្ធឈ្មោះ [redacted] ចាស់ស មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ វណ្ណា (ស) ម្ដាយឈ្មោះ [redacted] នៅ(រ) ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន៖គ្មាន។(ក្នុងឃុំ)

ដីកាបង្គាប់ឃុំឱ្យខ្លួនលេខ ៤៧៤ "ឃខ"/ខ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិកំបោរអរ ឃុំខ្វាវ ស្រុកអង្គជីក្រែង ខេត្តសៀមរាប មុខរបរកសិករ នៅលីវ ឪពុកឈ្មោះ[redacted] ហេង (ស) ម្ដាយឈ្មោះ[redacted] ផាត(ស)។(គេចខ្លួន)



Scanned with CamScanner

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៦អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង០០ នាទី នៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយធ្វើការឃាត់ខ្លួនបានឈ្មោះ [redacted]រិន ភេទប្រុស អាយុ៣៨ឆ្នាំ និងធ្វើការឆែកឆេរដកហូតបានម្សៅក្រាមពណ៌សថ្លា ចំនួន០៣កញ្ចប់ ទម្ងន់សុទ្ធ២.៣៩ក្រាម រួមជាមួយសម្ភារៈវេចខ្ចប់ និងប្រើប្រាស់គ្រឿងញៀនមួយចំនួន។ នៅពេលឃាត់ខ្លួនបានហើយសមត្ថកិច្ចបានសាកសួរចម្លើយឈ្មោះ [redacted] រិន ឆ្លើយសារភាពថាគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាន គឺទិញពីឈ្មោះ ហេង ហុន កាលពីថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២៤ មួយកញ្ចប់តម្លៃ ២០០.០០០ (ម្ភៃម៉ឺន) រៀល ហើយយកមករំលែកលក់ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ មួយកញ្ចប់តម្លៃ ៤០.០០០ (បួនម៉ឺន) រៀល។ ក្រោយពីសាកសួររួចសមត្ថកិច្ចបានធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] រិន ជាលទ្ធផលវិជ្ជមានសារធាតុញៀន ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១០៩៣ អយក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៨៦៨ អ.យ.ក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤។

-បានឃើញ ដីកាដំណោះស្រាយលេខ ៦៣៩៦ ពស.ព្រស/ឧ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១០៤៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តសៀមរាប។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] រិន បានឆ្លើយថា មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន ដោយសារខ្លួនបានលក់គ្រឿងញៀន នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ទៅឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះ លក់នៅនឹងផ្ទះខ្លួនចំនួន១កញ្ចប់តម្លៃ ៤០.០០០ (បួនម៉ឺន) រៀល។ លុះដល់ម៉ោង ១២ ថ្ងៃត្រង់ ស្រាប់តែសមត្ថកិច្ចចុះមកឃាត់ខ្លួន ហើយធ្វើការឆែកឆេរនៅក្នុងផ្ទះខ្លួន រកឃើញគ្រឿងញៀនចំនួន ៣ កញ្ចប់ ទម្ងន់សុទ្ធ ២.៣៩ ក្រាម និងថង់ច្រកគ្រឿងញៀនរួមជាមួយឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ដែលខ្លួនទុកនៅលើគ្រែក្បាលដំណេក។ គ្រឿងញៀននេះ ខ្លួនបានទិញពីឈ្មោះ ហុន ភេទប្រុស អាយុប្រហែល៣៣ឆ្នាំ រស់នៅភូមិសំរោង ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ គ្រឿងញៀនដែលខ្លួនទិញពីឈ្មោះ ហុន លើកចុងក្រោយ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ ចំនួន១កញ្ចប់តម្លៃ ២០០.០០០(ម្ភៃម៉ឺន)រៀល ដោយឈ្មោះ ហុន យកគ្រឿងញៀននេះមកឱ្យខ្លួនដល់ផ្ទះ ហើយខ្លួនបានរំលែកលក់បន្តនិងប្រើប្រាស់ខ្លះ ដោយបានលក់គ្រឿងញៀនទៅឱ្យគេចុងក្រោយថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ហើយខ្លួនប្រើប្រាស់គ្រឿងញៀនលើកចុងក្រោយតែម្នាក់ឯងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថ្លែងសុំថា**

ក្រោយពីបានដេញដោលចប់សព្វគ្រប់ ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយ



Scanned with CamScanner

ខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុប្រាកដមែន ដូច្នេះសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៨៦៨ អ.យ.គ/២៤ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ ទុកជាបានការ និងស្នើសុំទៅក្រុមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពេលដេញដោលនាពេលសវនាការរួចមក កូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី ដោយសារកត្តាជីវភាព មានឪពុកម្តាយវ័យចាស់ជរា និងមានកូនតូចៗក្នុងបន្ទុក និងមានជីវភាពខ្វះខាតដោយសារសមត្ថភាពនៃការយល់ដឹងនូវមានកម្រិតផងនោះ ខ្លួនសំណូមពរទៅក្រុមជំនុំជម្រះពិចារណាផ្តល់នូវស្ថានសម្រាលទោសឱ្យកូនក្តីខ្លួនផង។

## សំណូមពរសម្តីចុងក្រោយរបស់ជនជាប់ចោទ

ខ្លួនស្នើសុំទៅក្រុមជំនុំជម្រះមេត្តាសម្រេចបន្ធូរបន្ថយទោសដល់រូបខ្លួនផង ខ្លួនដឹងអំពីកំហុសហើយ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តសៀមរាប
## យល់ឃើញថា

១/-កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង០០ នាទី នៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយធ្វើការឃាត់ខ្លួនបាន ឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ និងធ្វើការឆែកឆេរដកហូតបានម្សៅក្រាមពណ៌សថ្លា ចំនួន០៣កញ្ចប់ ទម្ងន់សុទ្ធ២.៣៩ក្រាម រួមជាមួយសម្ភារៈវេចខ្ចប់ និងប្រើប្រាស់គ្រឿងញៀនមួយចំនួន។ នៅពេលឃាត់ខ្លួនបានហើយ សមត្ថកិច្ចបានសាកសួរចម្លើយឈ្មោះ [redacted] រិន ឆ្លើយសារភាពថាគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាន គឺទិញពីឈ្មោះ [redacted] ហុន កាលពីថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២៤ មួយកញ្ចប់តម្លៃ ២០០.០០០ (ម្ភៃម៉ឺន) រៀល ហើយយកមកវិចែកលក់ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ មួយកញ្ចប់តម្លៃ ៤០.០០០ (បួនម៉ឺន) រៀល។ ក្រោយពីសាកសួររួចសមត្ថកិច្ចបានធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] រិន ជាលទ្ធផលវិជ្ជមានសារធាតុញៀន

២/-តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមចម្លើយសារភាពរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុពាក់ព័ន្ធអាចបញ្ជាក់ថា ពិតជាមានករណី ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣-១៦ ខែឧសភា ឆ្នាំ២០២៤ បង្កឡើងដោយឈ្មោះ [redacted] រិន និងឈ្មោះ [redacted] ហុន ប្រាកដមែន។



Scanned with CamScanner

៣/-តាមដីកាដំណោះស្រាយលេខ ៦៣៩៦ ពស.ព្រស/ឧ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប បានបញ្ជូនឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ទៅជំនុំជម្រះពីបទ៖ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣ និងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន **ឃើញថា** នេះជាសមត្ថកិច្ចសាលាជំនុំជម្រះនៃសាលាដំបូងខេត្តសៀមរាប ផ្អែកតាមមាត្រា២៨៩ និងមាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤/-ជនជាប់ចោទបានឆ្លើយសារភាពថា មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន ដោយសារខ្លួនបានលក់គ្រឿងញៀន នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ទៅឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះ លក់នៅនឹងផ្ទះខ្លួនចំនួន១កញ្ចប់ តម្លៃ ៤០.០០០(បួនម៉ឺន)រៀល លុះដល់ម៉ោង ១២ ថ្ងៃត្រង់ ស្រាប់តែសមត្ថកិច្ចចុះមកឃាត់ខ្លួន ហើយធ្វើការឆែកឆេរនៅក្នុងផ្ទះខ្លួន រកឃើញគ្រឿងញៀនចំនួន ៣ កញ្ចប់ ទម្ងន់សុទ្ធ ២.៣៩ ក្រាម និងថង់ច្រកគ្រឿងញៀនរួមជាមួយឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ដែលខ្លួនទុកនៅលើគ្រែក្បាលដំណេក គ្រឿងញៀននេះ ខ្លួនបានទិញពីឈ្មោះ ហុន ភេទប្រុស អាយុប្រហែល៣៣ឆ្នាំ រស់នៅភូមិសំរោង ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។

៥/-តាមកំណត់ហេតុស្តីពីការបើក បិទកញ្ចប់វត្ថុតាង ដែលសង្ស័យថាជាថ្នាំញៀន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប មានស្នាមមេដៃជនជាប់ចោទឈ្មោះ [redacted] រិន ដោយបានច្របល់បញ្ចូលគ្នាឱ្យស្មើសាច់រួចថ្លឹងដោយជញ្ជីងម៉ា QC PASS 500g/0.01 មានទម្ងន់សុទ្ធ ៣ (បី)ក្រាម រួចបានវែកចែកជា ២(ពីរ)កញ្ចប់តូចៗ ដោយកញ្ចប់**ទីមួយ** មានទម្ងន់សុទ្ធចំនួន ១.១ក្រាម មកដាក់ចូលថង់ពណ៌ស និងដាក់ចូលក្នុងស្រោមសំបុត្រពណ៌ស រួចបិទជិតបញ្ជូនទៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីធ្វើកោសល្យវិច័យ និងកញ្ចប់**ទីពីរ** មានទម្ងន់សុទ្ធ ១.៤៨ ក្រាម ដាក់ក្នុងស្រោមសំបុត្រពណ៌សបិទជិត ប្រគល់ឱ្យប្រធានលេខាធិការដ្ឋានដើម្បីរក្សាទុក។

៦/-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៥១៣២៨/២៤** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានស្នាមមេដៃជនជាប់ចោទឈ្មោះ វណ្ណា រិន ជាលទ្ធផលនិងការសន្និដ្ឋានគឺ៖សំណាកជាគ្រឿងញៀនប្រភេទម្សៅថ្លា ឈ្មោះ **មេតំហ្វេតាមីន** ដែលមានកម្រិតភាពសុទ្ធ **៧៦,៨២%** នៃទម្ងន់សរុប។

***មេតំហ្វេតាមីន** ស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុង តារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

***ដូចនេះ** យកកម្រិតភាពសុទ្ធ **៧៦,៨២%** គុណនឹងទម្ងន់ដើមនៃម្សៅក្រាមពណ៌សទម្ងន់សុទ្ធ ៣ ក្រាម ចែកនឹង(%) ជាលទ្ធផលមានទម្ងន់ **២,៣០** ក្រាម ដែលស្ថិតក្នុងមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧/-អំពើរបស់ជនជាប់ចោទ មានចេតនាទុច្ចរិត ហើយជនជាប់ចោទមានកាយសម្បទាគ្រប់គ្រាន់ស្ថិតក្នុងវ័យដែលអាចដឹងខុសត្រូវបាន ហើយរាល់អំពើរបស់ជនជាប់ចោទសុទ្ធតែឆ្លងកាត់នូវការពិចារណាជាមុន ហើយអំពើប្រព្រឹត្តនេះ បានបង្កអោយមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គមជាពិសេសខុសនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលបានចូលជាធរមាន។



Scanned with CamScanner

៨/-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់កំណត់ពិរុទ្ធភាពលើឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ៖ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩/-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៨៦៨ អយក/២៤ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ ទុកជាបានការ និងស្នើសុំសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ យល់ឃើញថា ការស្នើសុំនេះមានលក្ខណៈត្រឹមត្រូវ គប្បីចៅក្រមជំនុំជម្រះពិនិត្យនិងសម្រេចតាមច្បាប់។

១០/-សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ថា កូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី ដោយសារកត្តាជីវភាព មានឪពុកម្តាយវ័យចាស់ជរា និងមានកូនតូចៗក្នុងបន្ទុកនិងមានជីវភាពខ្វះខាតដោយសារសមត្ថភាពនៃការយល់ដឹងនូវមានកម្រិតផងនោះ ខ្លួនសំណូមពរចៅក្រមជំនុំជម្រះពិចារណាផ្តល់នូវស្ថានសម្រាលទោសឱ្យកូនក្តីខ្លួនផង គប្បីចៅក្រមជំនុំជម្រះពិនិត្យនិងសម្រេចតាមច្បាប់។

១១/-វត្ថុចាប់យកតាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុដែលចាប់យកលេខ ៣១៨ វត.ព្រស/២៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប មានដូចខាងក្រោម ៖

ក.ស្រោមសំបុត្រពណ៌សបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] រិន និងហត្ថលេខាលោក [redacted] សុទ្ធារ៉ូ ចំនួន០១។

ខ.ស្រោមសំបុត្រពណ៌ខ្លឹមខ្នុរបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] រិន និងហត្ថលេខាលោក [redacted] សុទ្ធារ៉ូ ចំនួន០១កញ្ចប់។

គ.ទូរស័ព្ទម៉ាក VIVO មិនស្គាល់ម៉ូដែល ពណ៌ខ្មៅ លាយ ពណ៌ខៀវ(មានស៊ីម Metfone ចំនួន០២) ចំនួន ០១គ្រឿង។

ឃ.ទូរស័ព្ទម៉ាក VIVO មិនស្គាល់ម៉ូដែល ពណ៌ស្វាយ(សំបកចាស់) អត់មានស៊ីម ចំនួន០១គ្រឿង។

ង.ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល TA-1174 ពណ៌ខ្មៅ អត់មានស៊ីម ចំនួន០១គ្រឿង។

ចំពោះវត្ថុចាប់យកខាងលើនេះ ជាមធ្យោបាយដែលជនជាប់ចោទយកមកប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសហើយជនជាប់ចោទបានទទួលស្គាល់កំហុស ដូចនេះគប្បីសម្រេចរឹបអូស ស្របតាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

១២/-ក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ បានគេចខ្លួន ដូច្នេះគប្បីអនុវត្តចេញដីកាបង្គាប់ឱ្យចាប់និងឃុំខ្លួនលើជនជាប់ចោទរូបនេះ ស្របតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទមានដូចខាងក្រោម៖

ក-ឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល។



Scanned with CamScanner

ពីបទ៖ **ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ** និងពិន័យជាប្រាក់ចំនួន **៤.០០០.០០០(បួនលាន)**រៀល។

ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកតាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុដែលចាប់យកលេខ ៣១៨ វត.ព្រស/២៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប មានដូចខាងក្រោម ៖

ក.ស្រោមសំបុត្រពណ៌សបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] រិន និងហត្ថលេខាលោក សាក់ សុទ្ធារ៉ូ ចំនួន០១។

ខ.ស្រោមសំបុត្រពណ៌ខ្ចីមខ្ចុលបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] រិន និងហត្ថលេខាលោក សាក់ សុទ្ធារ៉ូ ចំនួន០១កញ្ចប់។

គ.ទូរស័ព្ទម៉ាក VIVO មិនស្គាល់ម៉ូដែល ពណ៌ខ្មៅ លាយ ពណ៌ខៀវ(មានស៊ីម Metfone ចំនួន០២) ចំនួន ០១គ្រឿង។

ឃ.ទូរស័ព្ទម៉ាក VIVO មិនស្គាល់ម៉ូដែល ពណ៌ស្វាយ(សំបកចាស់) អត់មានស៊ីម ចំនួន០១គ្រឿង

ង.ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល TA-1174 ពណ៌ខ្មៅ អត់មានស៊ីម ចំនួន០១គ្រឿង។

**ត្រូវរឹបអូស ផ្អែកតាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។**

៣-ចេញដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ហុន ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៧ ផ្អែកតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហុន និងធ្វើការប្រកាស នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤។

"ទុកសិទ្ធិប្តឹងទាស់ និង បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់"

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១១ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

សៀមរាប ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
|---|---|
| [redacted] | [redacted] |



Scanned with CamScanner